# ព្រឹទ្ធសភា
## នៃព្រះរាជាណាចក្រកម្ពុជា

## សមិទ្ធផល១០ឆ្នាំ
## (២៥ ខែមីនា ឆ្នាំ១៩៩៩-២០០៩)

# ព្រឹទ្ធសភា
# នៃព្រះរាជាណាចក្រកម្ពុជា

## សមិទ្ធផល១០ឆ្នាំ

(២៥ ខែមីនា ឆ្នាំ១៩៩៩-២០០៩)

ព្រឹទ្ធសភា នីតិកាលទី១ (១៩៩៩-២០០៥)

## សមាសភាព សមាជិកព្រឹទ្ធសភា នីតិកាលទី១ (១៩៩៩-២០០៥)
## ថ្នាក់ដឹកនាំព្រឹទ្ធសភា

សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម
ប្រធានព្រឹទ្ធសភា

សម្ដេច ស៊ីសុវត្ថិ ជីវ័នមុនីរក្ស
អនុប្រធានទី១ ព្រឹទ្ធសភា

ឯកឧត្តម ឆៅ ប៊ុនស្រ៊ី
អនុប្រធានទី២ ព្រឹទ្ធសភា

# សមាជិក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី១

សម្ដេច **ស៊ីសុវត្ថិ ជីវ័នមុនីរក្ស**
អនុប្រធានទី១

សម្ដេចអគ្គមហាធម្មពោធិសាល
**ជា ស៊ីម**
ប្រធាន

ឯកឧត្ដម **ឆៅ ប៊ុនស្រ៊ី**
អនុប្រធានទី២

លោកជំទាវ **ម៉ែន ម៉ាលី**
សមាជិកា

សម្ដេចរាជបុត្រីព្រះរៀម
**នរោត្តម បុប្ផាទេវី**
សមាជិកា

ឯកឧត្ដម **ចាន់ គិន**
សមាជិក

ឯកឧត្ដម **ជា ថេង**
សមាជិក

លោកជំទាវ **តី បូរ៉ាស៊ី**
សមាជិកា

ឯកឧត្ដម **ញ៉ុក ប៊ុនឈឿន**
សមាជិក

ឯកឧត្ដម **គង់ គាំ**
សមាជិក

ឯកឧត្ដម **ស៊ឹង អៀម**
សមាជិក

ឯកឧត្ដម **សាប៊ុ ចាចា**
សមាជិក

# គណៈកម្មការសិទ្ធិមនុស្ស និងទទួលពាក្យបណ្ដឹង

លោកជំទាវ **ម៉ែន ម៉ាលី**
ប្រធាន

ឯកឧត្តម **អ៊ុង ធី**
អនុប្រធាន

ឯកឧត្តម **ឡាយ ឈុនសារ៉េត**
លេខាធិការ

ឯកឧត្តម **ភង ចន្ទ**
សមាជិក

ឯកឧត្តម **អ៊ុក មឿន**
សមាជិក

# គណៈកម្មការហិរញ្ញវត្ថុ និងធនាគារ

សម្ដេចរាជបុត្រីព្រះរៀម
**នរោត្តម បុប្ផាទេវី**
ប្រធាន

លោកជំទាវ **ពុំ ស៊ីចាន់**
អនុប្រធាន

ឯកឧត្តម **ឆាយ ចិនឡាយ**
លេខាធិការ

ឯកឧត្តម **ម៉ាន់ ម៉ាត់**
សមាជិក

ឯកឧត្តម **អ៊ុង ប៊ុនអាង**
សមាជិក

# គណៈកម្មការសេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន

ឯកឧត្តម **ចាន់ គិន**
ប្រធាន

ឯកឧត្តម **ហួត ប៉ុងលី**
អនុប្រធាន

ឯកឧត្តម **យ៉ង់ សែម**
លេខាធិការ

ឯកឧត្តម **ទ្រាក់ វ៉ាន់នី**
សមាជិក

ឯកឧត្តម **ហ៊ុត ទ្រី**
សមាជិក

## គណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត និងបោសសម្អាត

ឯកឧត្តម **ជា ចេដ្ឋ**
ប្រធាន

ឯកឧត្តម **ធា ចំរ៉ាត់**
អនុប្រធាន

ឯកឧត្តម **សេក សំអៀត**
លេខាធិការ

ឯកឧត្តម **អ៊ុង ស៊ីម**
សមាជិក

ឯកឧត្តម **ចៅ ផល្លី**
សមាជិក

# គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន

លោកជំទាវ **ទី បូរ៉ាស៊ី**
ប្រធាន

ព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ សិរីរត្ន**
អនុប្រធាន

ឯកឧត្តម **និត រាម**
លេខាធិការ

លោកជំទាវ **ឈុក ឈីម**
សមាជិកា

ឯកឧត្តម **ជា គីម**
សមាជិក

# គណៈកម្មការនីតិកម្ម

ឯកឧត្តម អ៊ុក ប៊ុនឈឿន
ប្រធាន

ឯកឧត្តម រស់ ឆេង
អនុប្រធាន

ឯកឧត្តម ថុង ចន់
លេខាធិការ

លោកជំទាវ មុិច សុម៉ាលី
សមាជិកា

ឯកឧត្តម ថាច់ សេដ្ឋា
សមាជិក

# គណៈកម្មការអប់រំ ធម្មការ វប្បធម៌ និងទេសចរណ៍

ឯកឧត្តម **គង់ គាំ**
ប្រធាន

ឯកឧត្តម **តូច សាត់**
អនុប្រធាន

អ្នកម្នាង **នរោត្តម ឌីយ៉ាត**
លេខាធិការ

ឯកឧត្តម **ឆ្នាំ ប៊ុនស្រ៊ុន**
សមាជិក

ឯកឧត្តម **គង់ សារាជ**
សមាជិក

# គណៈកម្មការសុខាភិបាល សង្គមកិច្ច ការងារ និងកិច្ចការនារី

ឯកឧត្តម **ស៊ីង អឿម**
ប្រធាន

ឯកឧត្តម **ឈា ចាំង**
អនុប្រធាន

លោកជំទាវ **សម កន្និដ្ឋា**
លេខាធិការ

លោកជំទាវ **មាន សំអាន**
សមាជិកា

ឯកឧត្តម **ម៉េង វីតា**
សមាជិក

# គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម ថាមពល និងពាណិជ្ជកម្ម

ឯកឧត្តម **សាម៉ុ ឃាចា**
ប្រធាន

ឯកឧត្តម **ឈិត គីមយាត**
អនុប្រធាន

ឯកឧត្តម **ហាស សារ៉េន**
លេខាធិការ

ឯកឧត្តម **ប៉ឿយ គើក**
សមាជិក

ឯកឧត្តម **ខៀច សួន**
សមាជិក

# សមាជិក សមាជិកាគ្រប់គណៈកម្មការព្រឹទ្ធសភា

ឯកឧត្តម **អ៊ុំ ម៉ាន្នីរ៉ិន**
សមាជិក (តំណាងព្រះមហាក្សត្រ)

ឯកឧត្តម **អៀវ បណ្ណាការ**
សមាជិក (តំណាងព្រះមហាក្សត្រ)

ឯកឧត្តម **ឆេព ខន**
សមាជិក

ឯកឧត្តម **ស៊ីម កា**
សមាជិក

ឯកឧត្តម **ស៊ើយ កែវ**
សមាជិក

ឯកឧត្តម **ម៉ែន សារុន**
សមាជិក

ឯកឧត្តម **រស់ ស្រេង**
សមាជិក

ឯកឧត្តម **ជា សុន**
សមាជិក

## សមាជិក សមាជិកាក្រៅគណៈកម្មការព្រឹទ្ធសភា

ឯកឧត្តម **ប៉ែន ប៉ាត់**
សមាជិក

ឯកឧត្តម **អ៊ុំ សារិទ្ធ**
សមាជិក

ឯកឧត្តម **ជ័យ សាផុន**
សមាជិក

លោកជំទាវ **ឡាក់ អួន**
សមាជិកា

ឯកឧត្តម **សោម សុផា**
សមាជិក

## ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន

ឯកឧត្តម **អ៊ុំ សារីទ្ធ**
អគ្គលេខាធិការ

ឯកឧត្តម **ញឹក ឆៃអេង**
អគ្គលេខាធិការរង

ព្រឹទ្ធសភា នីតិកាលទី២ (២០០៦-បច្ចុប្បន្ន)

## សមាសភាព សមាជិកព្រឹទ្ធសភា នីតិកាលទី២ (២០០៦-២០១២)
## ថ្នាក់ដឹកនាំព្រឹទ្ធសភា

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**
**ប្រធានព្រឹទ្ធសភា**

សម្តេច ស៊ីសុវត្ថិ ជីវ័នមុនីរក្ស
អនុប្រធានទី១ ព្រឹទ្ធសភា

ឯកឧត្តម ទេព ងន
អនុប្រធានទី២ ព្រឹទ្ធសភា

# សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី២

សម្តេច **ស៊ីសុវត្ថិ ជីវ័នមុនីរក្ស**
អនុប្រធានទី១

**សម្តេចអគ្គមហាធម្ម**
**ពោធិសាល ជា ស៊ីម**
ប្រធាន

ឯកឧត្តម **ទេព ងន**
អនុប្រធានទី២

លោកជំទាវ **ម៉ែន ម៉ាលី**
សមាជិកា

ឯកឧត្តម **ជា ចេដ្ឋ**
សមាជិក

ឯកឧត្តម **ចាន់ គិន**
សមាជិក

ឯកឧត្តម **គង់ សារាជ**
សមាជិក

លោកជំទាវ **ទី បូរ៉ាស៊ី**
សមាជិកា

ឯកឧត្តម **អ៊ុក ប៊ុនឈឿន**
សមាជិក

ឯកឧត្តម **គង់ គាំ**
សមាជិក

លោកជំទាវ **ខូត ឆចផ្កា**
សមាជិកា

ឯកឧត្តម **សាប៊ុ ឆាចា**
សមាជិក

# គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្ដឹង និងអង្កេត

លោកជំទាវ **ម៉ែន ម៉ាលី**
ប្រធាន

ឯកឧត្តម **សេក សំអៀត**
អនុប្រធាន

ឯកឧត្តម **គីម ណារិន**
លេខាធិការ

ឯកឧត្តម **ភង ចន្ទ**
សមាជិក

ឯកឧត្តម **អ៊ុក គង់**
សមាជិក

# គណៈកម្មការហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

ឯកឧត្តម **ជា ចេដ្ឋ**
ប្រធាន

ឯកឧត្តម **ពៅ សិទ្ធិ**
អនុប្រធាន

ឯកឧត្តម **អ៊ុំ សារិទ្ធ**
លេខាធិការ

ឯកឧត្តម **ថ៉ាន់ ម៉ាត់**
សមាជិក

ឯកឧត្តម **ឆាត់ ឈឿម**
សមាជិក

# គណៈកម្មការសេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន

ឯកឧត្តម **ចាន់ ភិន**
ប្រធាន

ឯកឧត្តម **អ៊ឹង ហួត**
អនុប្រធាន

លោកជំទាវ **មាន សំអាន**
លេខាធិការ

ឯកឧត្តម **ជ័យ សាផុន**
សមាជិក

ឯកឧត្តម **ម៉ុង ឫទ្ធី**
សមាជិក

## គណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ

ឯកឧត្តម **គង់ សារាជ**
ប្រធាន

ឯកឧត្តម **ប៉ុក កុសល**
អនុប្រធាន

ឯកឧត្តម **ឡាយ អ៊ីពិសិដ្ឋ**
លេខាធិការ

ឯកឧត្តម **រស់ ស្រេង**
សមាជិក

ឯកឧត្តម **ស៊ើយ កែវ**
សមាជិក

# គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន

លោកជំទាវ **ទី បូរ៉ាស៊ី**
ប្រធាន

ឯកឧត្តម **ខា គីម**
អនុប្រធាន

លោកជំទាវ **ឈូក ឈឹម**
លេខាធិការ

ឯកឧត្តម **ទិត រាម**
សមាជិក

ឯកឧត្តម **ហុង ទូហាយ**
សមាជិក

# គណៈកម្មការនីតិកម្ម និងយុត្តិធម៌

ឯកឧត្តម **អ៊ុក ប៊ុនឈឿន**
ប្រធាន

ឯកឧត្តម **យ៉ង់ សែម**
អនុប្រធាន

ឯកឧត្តម **ជា សុន**
លេខាធិការ

ឯកឧត្តម **ជុំ ចន់**
សមាជិក

ឯកឧត្តម **ចៀយ គើក**
សមាជិក

# គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ និងទេសចរណ៍

ឯកឧត្តម **គង់ គាំ**
ប្រធាន

ឯកឧត្តម **ឆ្នាំ ប៊ុនស្រុន**
អនុប្រធាន

ឯកឧត្តម **តូច សារ៉ាក់**
លេខាធិការ

លោកជំទាវ **ឡាក់ អួន**
សមាជិកា

ឯកឧត្តម **សោម សុផា**
សមាជិក

# គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី

លោកជំទាវ **ខូត ឆងផ្កា**
ប្រធាន

លោកជំទាវ **ពុំ ស៊ីចាន់**
អនុប្រធាន

ឯកឧត្តម **សួន ឈន់**
លេខាធិការ

លោកជំទាវ **ទ្រី ស៊ិត**
សមាជិកា

ឯកឧត្តម **ម៉ាន់ ស៊ីវឿន**
សមាជិក

# គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ឯកឧត្តម **សាប៊ូ បាចា**
ប្រធាន

ឯកឧត្តម **ឈិត គីមយ៉ាត**
អនុប្រធាន

ឯកឧត្តម **ពុធ ខុច**
លេខាធិការ

ឯកឧត្តម **អ៊ុង ទី**
សមាជិក

ឯកឧត្តម **ពុត ជួប**
សមាជិក

# សមាជិក សមាជិកា នៅក្រៅគណៈកម្មការព្រឹទ្ធសភា

ឯកឧត្តម **អ៊ុំ ម៉ាន្នូរីន**
សមាជិក (តំណាងព្រះមហាក្សត្រ)

ឯកឧត្តម **អៀង បណ្ណាការ**
សមាជិក (តំណាងព្រះមហាក្សត្រ)

ឯកឧត្តម **ឈា ថាវិទ**
សមាជិក

សម្តេចរាជបុត្រីព្រះរៀម
**នរោត្តម បុប្ផាទេវី**
សមាជិកា (តំណាងរដ្ឋសភា)

ឯកឧត្តម **ឡាវ ម៉េងឃីន**
សមាជិក

ឯកឧត្តម **ស៊ុម ភា**
សមាជិក

ឯកឧត្តម **ឈឹម សាខន**
សមាជិក

ឯកឧត្តម **ម៉ែន សារុន**
សមាជិក

## សមាជិក សមាជិកានៅក្រៅគណៈកម្មការព្រឹទ្ធសភា

ឯកឧត្តម **ស៊ី គង់ទ្រីវ**
សមាជិក

ឯកឧត្តម **ភុក អាន**
សមាជិក

ឯកឧត្តម **លី យ៉ុងផាត់**
សមាជិក

ឯកឧត្តម **ប៉េង ធាត់**
សមាជិក

ឯកឧត្តម **ចៅ ប៊ុនស្រ៊ី**
សមាជិក

## ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន

ឯកឧត្តម **អ៊ុំ សារិទ្ធ**
អគ្គលេខាធិការ

ឯកឧត្តម **ញ៉ឹក ឆៃអេង**
អគ្គលេខាធិការរង

# សមិទ្ធផល១០ឆ្នាំ
# ព្រឹទ្ធសភា

(២៥ ខែមីនា ឆ្នាំ១៩៩៩-២០០៩)

# មាតិកា


**សេចក្តីផ្តើម** ១

**I. ប្រវត្តិស្ថាប័នព្រឹទ្ធសភា** ១

**II. សមិទ្ធផល១០ឆ្នាំរបស់ព្រឹទ្ធសភា** ៣

**១. មុខងារនីតិកម្ម** ៣

ក-សម័យប្រជុំពេញអង្គ និងវិសាមញ្ញ ៣

ខ-សកម្មភាពរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ៤

គ-តារាងសង្ខេបស្តីពីសកម្មភាពរបស់ថ្នាក់ដឹកនាំ ៥

ឃ-សកម្មភាពរបស់គណៈកម្មការជំនាញទាំង៩ ៥

ង-គណៈកម្មការពិសេសរបស់ព្រឹទ្ធសភា ៦

**២. មុខងារតំណាង** ៧

**៣. មុខងារត្រួតពិនិត្យ** ៩

ក-គណៈកម្មការជំនាញទាំង៩របស់ព្រឹទ្ធសភា ៩

ខ-ក្រុមសមាជិកាព្រឹទ្ធសភា ៩

**៤. មុខងារព័ត៌មាន** ១០

**៥. ការងារទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ** ១០

ក-ការងារទំនាក់ទំនងសាធារណៈ ១០

ខ-កិច្ចសហប្រតិបត្តិការអន្តរជាតិ ១១

គ-ការផ្លាស់ប្តូរគណៈប្រតិភូជាន់ខ្ពស់សភា ១១

ឃ-លទ្ធផលនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ១២

**៦. សកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា** ៤០

ក-គោលការណ៍គ្រប់គ្រងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ៤០

១-សេចក្តីសម្រេចរួម ៤២

២-គោលនយោបាយ ៤៣

ខ-ការបណ្តុះបណ្តាលធនធានមនុស្សក្នុង និងក្រៅប្រទេស ៤៦
១-ការបណ្តុះបណ្តាលក្នុងប្រទេស ៤៦
២-ការបណ្តុះបណ្តាលនៅក្រៅប្រទេស ៤៧
គ-ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់ស្ថាប័នព្រឹទ្ធសភា ៤៧
III-**ចក្ខុវិស័យរបស់ព្រឹទ្ធសភារយៈពេល១០ឆ្នាំ** ៥៦
**សេចក្តីសន្និដ្ឋាន** ៥៧

## សេចក្តីផ្តើម

ព្រឹទ្ធសភាជាស្ថាប័នជាតិជាន់ខ្ពស់ដែលមានអំណាចនីតិបញ្ញត្តិ មានភារកិច្ចពិនិត្យ និងឱ្យយោបល់លើអត្ថបទច្បាប់ និងសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល ។

ក្នុងរយៈពេល១០ឆ្នាំកន្លងមកនេះ ក្នុងនាមជាចំណែកមួយនៃអង្គនីតិបញ្ញត្តិកម្ពុជា ព្រឹទ្ធសភាបានចូលរួមយ៉ាងសកម្មថ្លៃថ្លា ក្នុងការពង្រឹងនីតិរដ្ឋ និងការពង្រឹងពង្រីកដំណើរការប្រជាធិបតេយ្យភាវូបនីយកម្ម សង្គម សំដៅធានាការអភិវឌ្ឍ សេដ្ឋកិច្ច សង្គមជាតិ និងបានការពារផលប្រយោជន៍ទូទៅរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងប្រទេស និងប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ ។

ជាពិសេសព្រឹទ្ធសភាបានផ្តល់វិភាគទានដ៏សំខាន់ ដល់ការកែទម្រង់ទាំងឡាយ ដែលជាអាទិភាពរបស់រាជរដ្ឋាភិបាល និងការធ្វើសមាហរណកម្មកម្ពុជាចូលទៅក្នុងក្របខ័ណ្ឌតំបន់ និងអន្តរជាតិ ។

## I. ប្រវត្តិស្ថាប័នព្រឹទ្ធសភា

ប្រព័ន្ធសភាពីរថ្នាក់ បានកើតឡើងនៅក្នុងប្រទេសកម្ពុជា តាំងពីពេលដែលរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា បានកកើតឡើងជាលើកដំបូង នាឆ្នាំ ១៩៤៧ ។ ប៉ុន្តែអាស្រ័យដោយឥទ្ធិពលនៃសង្គ្រាមត្រជាក់ លើសកលលោក បានធ្វើឱ្យប្រទេសកម្ពុជា ត្រូវធ្លាក់ចូលទៅក្នុងសង្គ្រាមរ៉ាំរ៉ៃអស់រយៈពេលជាងពីរទសវត្សរ៍ ដែលបានធ្វើឱ្យគ្រប់ហេដ្ឋារចនាសម្ព័ន្ធសង្គម ត្រូវបំផ្លាញខ្ទេចខ្ទី និងបាត់បង់ទាំងស្រុងធ្លាក់ដល់កម្រិតសូន្យ នាសម័យកាលដ៏ខ្មៅងងឹត នៃរបបកម្ពុជាប្រជាធិបតេយ្យ ។

កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ បានកំណត់ឱ្យមានការបោះឆ្នោតជាសកល ដោយសេរី និងយុត្តិធម៌ក្នុងប្រទេសកម្ពុជាក្រោមការរៀបចំរបស់អាជ្ញាធរបណ្តោះអាសន្ន នៃអង្គការសហប្រជាជាតិប្រចាំ

នៅកម្ពុជាហៅកាត់ថា (UNTAC) ដើម្បីបញ្ចប់ជម្លោះ បង្កើតស្ថាប័នគ្រប់គ្រងប្រទេស និងកសាងនីតិរដ្ឋ។

បន្ទាប់ពីការបោះឆ្នោតជាសកលលើកដំបូង ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៣ សភាធម្មនុញ្ញមួយបានចាប់បដិសន្ធិឡើងនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៣ ដើម្បីតាក់តែងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។ រដ្ឋធម្មនុញ្ញនេះ ត្រូវបានសភាធម្មនុញ្ញអនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ និងបានចូលជាធរមាន នាថ្ងៃទី២៤ ខែឆ្នាំដដែល។ រដ្ឋធម្មនុញ្ញនេះបានកំណត់ឱ្យព្រះរាជាណាចក្រកម្ពុជា ស្ថិតក្រោមរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ។

អំណាចក្នុងការគ្រប់គ្រងរដ្ឋ ត្រូវបានបែងចែកដាច់ពីគ្នាជាបី គឺអំណាចនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការ។ នៅពេលរដ្ឋធម្មនុញ្ញបានចូលជាធរមាន សភាធម្មនុញ្ញបានក្លាយទៅជារដ្ឋសភានីតិកាលទី១ ហើយបានដំណើរការក្នុងនាមជាស្ថាប័ននីតិប្បញ្ញត្តិតែមួយគត់ របស់ព្រះរាជាណាចក្រកម្ពុជាពេញមួយនីតិកាល។

ក្រោយការបោះឆ្នោតជាសកល ជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២ នាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ វិបត្តិនយោបាយ ផ្ទៃក្នុងមួយបានកើតឡើង។ ដើម្បីដោះស្រាយវិបត្តិនេះ កិច្ចប្រជុំកំពូលរវាងថ្នាក់ដឹកនាំជាន់ខ្ពស់ នៃគណបក្សនយោបាយធំទាំងពីរ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិចបានប្រារព្ធឡើងពីថ្ងៃទី១២-១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ នាប្រាសាទខេមរិន្ទព្រះបរមរាជវាំង ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ដែលនៅពេលនោះ ព្រះអង្គទ្រង់ជាព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា។

តាមរយៈលទ្ធផលនៃកិច្ចប្រជុំកំពូលនេះ ស្ថាប័នព្រឹទ្ធសភា ត្រូវបានបង្កើតឡើង

និងក្លាយជាចំណែកមួយនៃស្ថាប័ននីតិប្បញ្ញត្តិជាតិ ដែលមានពីរថ្នាក់ បន្ទាប់ពីរដ្ឋធម្មនុញ្ញនីតិកាលទី២ បានធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។

ព្រឹទ្ធសភានីតិកាលទី១ កើតឡើងដោយការតែងតាំង និងមានអាណត្តិ៥ឆ្នាំ។ សមាជិកចំនួន៦១រូប ត្រូវបានជ្រើសរើសពីក្នុងចំណោមឥស្សរជនជាន់ខ្ពស់ នៃគណបក្សនយោបាយ ដែលមានអាសនៈនៅក្នុងរដ្ឋសភានីតិកាលទី២។ ព្រឹទ្ធសភានីតិកាលទី១ បានបើកសម័យប្រជុំលើកទី១ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩។

ព្រឹទ្ធសភានីតិកាលទី២ កើតឡើងដោយការបោះឆ្នោតជាអសកល នាថ្ងៃអាទិត្យ ទី២២ ខែមករា ឆ្នាំ២០០៦ ដោយមានអាណត្តិ៦ឆ្នាំ។ ក្នុងចំណោមសមាជិក៦១រូប មាន៥៧រូបត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាអសកល ០២រូបជ្រើសតាំងដោយរដ្ឋសភា និង០២រូបតែងតាំងដោយព្រះមហាក្សត្រ។ ព្រឹទ្ធសភានីតិកាលទី២ បានបើកសម័យប្រជុំដំបូង នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៦។

## II. សមិទ្ធផល១០ឆ្នាំរបស់ព្រឹទ្ធសភា

ព្រឹទ្ធសភាមានមុខងារសំខាន់ៗចំនួន៣ គឺមុខងារនីតិកម្ម មុខងារតំណាង និងមុខងារត្រួតពិនិត្យ។ ដោយឡែកគណៈកម្មការជំនាញទាំង៩ មានមុខងារនីតិកម្ម មុខងារព័ត៌មាន និងមុខងារត្រួតពិនិត្យ។

ក្នុងរយៈពេល១០ឆ្នាំ កន្លងមកនេះ ព្រឹទ្ធសភាបានខិតខំបំពេញការងារយ៉ាងសកម្ម ដោយទទួលបាននូវលទ្ធផលដូចតទៅ ÷

### ១. មុខងារនីតិកម្ម

ក្នុងមុខងារនីតិកម្ម ព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់លើអត្ថបទច្បាប់ ឬបញ្ហានានា ដែលរដ្ឋសភាបានបញ្ជូនមក។ ជាក់ស្តែងក្នុងរយៈពេល១០ឆ្នាំនេះ ព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់លើអត្ថបទច្បាប់បានចំនួន**២០៥** ក្នុងចំណោមអត្ថបទច្បាប់ចំនួន**២២៨** ដែលរដ្ឋសភាបានបញ្ជូនមក ។

#### ក. សម័យប្រជុំពេញអង្គ និងប្រជុំវិសាមញ្ញ

សម្រាប់នីតិកាលទី១ (១៩៩៩-២០០៥)៖ ក្នុងនីតិកាលទី១នេះ ព្រឹទ្ធសភា

បានបន្ត នីតិកាលរបស់ខ្លួនចំនួនពីរដង ម្តង០១ឆ្នាំ ដោយបានដំណើរការសម័យប្រជុំពេញអង្គចំនួន**១០**លើក កោះប្រជុំចំនួន**៩០**ដង និងកោះប្រជុំជាវិសាមញ្ញចំនួន**០៤**ដង ពិនិត្យ និងឱ្យយោបល់លើអត្ថបទច្បាប់បានចំនួន**១២៨** ក្នុងនោះមានអត្ថបទច្បាប់ចំនួន**០២** ដែលព្រឹទ្ធសភាបានស្នើឱ្យរដ្ឋសភាពិនិត្យ និងកែសម្រួលឡើងវិញគឺ ÷

១-ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន

២-ច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជន លើវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ។

ដោយឡែកអត្ថបទច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ព្រឹទ្ធសភាបានបដិសេធមិនទទួលយកមកពិនិត្យ និងពិចារណាឡើយ ។

| សម័យប្រជុំ | លើកទី១ | វិសាមញ្ញ | លើកទី២ | លើកទី៣ | លើកទី៤ | លើកទី៥ | លើកទី៦ | លើកទី៧ | លើកទី៨ | លើកទី៩ | វិសាមញ្ញ | លើកទី១០ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| កោះប្រជុំ | ០៩ | ០២ | ០៧ | ១០ | ១៥ | ១២ | ០៥ | ០៥ | ០៨ | ១៤ | ០២ | ០៥ |
| ចំនួនច្បាប់ | ១៤ | ០៣ | ០៤ | ១១ | ០៧ | ០៩ | ០៨ | ០៧ | ១២ | ២៨ | ០១ | ២៤ |

សម្រាប់នីតិកាលទី២ (២០០៦-២០១២) គិតត្រឹមខែមករា ឆ្នាំ២០០៩ : ព្រឹទ្ធសភាបានដំណើរការសម័យប្រជុំពេញអង្គ ចំនួន**០៥**លើក កោះប្រជុំចំនួន២៩ដង និងកោះប្រជុំវិសាមញ្ញចំនួន០៤ដង ពិនិត្យ និងឱ្យយោបល់លើអត្ថបទច្បាប់បានចំនួន**៧៧** ក្នុងចំណោមអត្ថបទច្បាប់ចំនួន**៩១** ដែលរដ្ឋសភាបានបញ្ជូនមក ។

| សម័យប្រជុំ | ដំបូង | លើកទី១ | វិសាមញ្ញ | លើកទី២ | លើកទី៣ | វិសាមញ្ញ | លើកទី៤ | វិសាមញ្ញ | លើកទី៥ |
|---|---|---|---|---|---|---|---|---|---|
| កោះប្រជុំ | ០១ | ០៤ | ០១ | ០៦ | ០៦ | ០២ | ០៨ | ០១ | ០២ |
| ចំនួនច្បាប់ | | ០៥ | ០៣ | ២២ | ១៤ | ០៥ | ២៣ | ០១ | ០៤ |

## ខ-សកម្មភាពរបស់គណៈកម្មាធិការអចិន្ត្រៃយ៍

ក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន គណៈកម្មាធិការអចិន្ត្រៃយ៍បានកោះប្រជុំចំនួន**១៣១**ដង ដើម្បីរៀបចំរបៀបវារៈ កំណត់កាលបរិច្ឆេទនៃការ

កោះប្រជុំព្រឹទ្ធសភា (ពេញអង្គ និងវិសាមញ្ញ) និងជ្រើសរើសលេខាធិការ សម្រាប់សម័យប្រជុំនីមួយៗ ព្រមទាំងពិនិត្យ និងសម្រេចលើការងារផ្ទៃក្នុងរបស់ព្រឹទ្ធសភា។

### គ_តារាងសង្ខេបស្តីពីសកម្មភាពរបស់ថ្នាក់ដឹកនាំ

| ថ្នាក់ដឹកនាំ | ដឹកនាំប្រជុំពេញអង្គ | ដឹកនាំប្រជុំគ.ក.អចិន្ត្រៃយ៍ | ប្រមុខរដ្ឋស្តីទី |
|---|---|---|---|
| សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធាន | ៩៨ដង | ៦៨ដង | ២៩ដង |
| សម្តេច **ស៊ីសុវត្ថិ ជីវ័នមុនីរក្ស** អនុប្រធានទី១ | ៦០ដង | ៥៤ដង | ០១ដង |
| ឯកឧត្តម **ទេព ងន** អនុប្រធានទី២ | ០៤ដង | ០៤ដង | ០០ |
| ឯកឧត្តម **ញឹក ប៊ុនឆៃ** អតីតអនុប្រធានទី២ | ០៤ដង | ០៦ដង | ០១ដង |
| ឯកឧត្តម **ឆៅ ប៊ុនស្រ៊ី** អតីតអនុប្រធានទី២ | ០០ | ០១ដង | ០០ |

### ឃ_សកម្មភាពរបស់គណៈកម្មការជំនាញទាំង៩

គណៈកម្មការជំនាញទាំង៩របស់ព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម ស្របតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់គណៈកម្មការនីមួយៗ ដោយបានដើរតួនាទីជាកូនព្រឹទ្ធសភាមួយ ដើម្បីសម្រេចឱ្យបាននូវមុខងារទាំង៣ ។

ក្នុងរយៈពេល១០ឆ្នាំនេះ គណៈកម្មការជំនាញទាំង៩ បានពិនិត្យ ពិភាក្សាលើសេចក្តីស្នើច្បាប់ សេចក្តីព្រាងច្បាប់ និងអត្ថបទច្បាប់ ព្រមទាំងបណ្តឹងតវ៉ា ដូចខាងក្រោម ÷

-គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត បានចូលរួមដោះស្រាយ និងបញ្ជូនពាក្យបណ្តឹងទៅស្ថាប័នមានសមត្ថកិច្ច ចំនួន**១.១៧១**ករណី និងបានពិនិត្យអត្ថបទច្បាប់ចំនួន **០២**។

-គណៈកម្មការហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម បានចូលរួមដោះស្រាយ និងបញ្ជូនពាក្យបណ្តឹងទៅស្ថាប័នមានសមត្ថកិច្ច ចំនួន**១០**ករណី និងបានពិនិត្យអត្ថបទច្បាប់ចំនួន**៥១**។

-គណៈកម្មការសេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន បានចូលរួមដោះស្រាយ និងបញ្ជូនពាក្យបណ្តឹង

ទៅស្ថាប័នមានសមត្ថកិច្ច ចំនួន**៥៨**ករណី និងបានពិនិត្យអត្ថបទច្បាប់ចំនួន**៣៤**។

-គណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ បានចូលរួមដោះស្រាយ និងបញ្ជូនពាក្យបណ្ដឹងទៅស្ថាប័នមានសមត្ថកិច្ច ចំនួន**៦៦៥**ករណី និងបានពិនិត្យអត្ថបទច្បាប់ចំនួន**១៥**។

-គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន បានចូលរួមដោះស្រាយ និងបញ្ជូនពាក្យបណ្ដឹងទៅស្ថាប័នមានសមត្ថកិច្ចចំនួន**៣៧**ករណី និងបានពិនិត្យអត្ថបទច្បាប់ចំនួន**២៦**។

-គណៈកម្មការនីតិកម្ម និងយុត្តិធម៌បានចូលរួមដោះស្រាយ និងបញ្ជូនពាក្យបណ្ដឹងទៅស្ថាប័នមានសមត្ថកិច្ចចំនួន **៤៣៥**ករណី និងបានពិនិត្យអត្ថបទច្បាប់ចំនួន**៣១**។

-គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ និងទេសចរណ៍ បានចូលរួមដោះស្រាយ និងបញ្ជូនពាក្យបណ្ដឹងទៅស្ថាប័នមានសមត្ថកិច្ច ចំនួន**៣៨**ករណី និងបានពិនិត្យអត្ថបទច្បាប់ចំនួន**០៧**។

-គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុវជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី បានចូលរួមដោះស្រាយ និងបញ្ជូនពាក្យបណ្ដឹងទៅស្ថាប័នមានសមត្ថកិច្ច ចំនួន**១២**ករណី និងបានពិនិត្យអត្ថបទច្បាប់ចំនួន**១២**។

-គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចូលរួមដោះស្រាយ និងបញ្ជូនពាក្យបណ្ដឹងទៅស្ថាប័នមានសមត្ថកិច្ច ចំនួន**៧៥**ករណី និងបានពិនិត្យអត្ថបទច្បាប់ចំនួន**២៧**។

### ខ-គណៈកម្មការពិសេសរបស់ព្រឹទ្ធសភា

ក្រៅពីគណៈកម្មការជំនាញទាំង**៩**ខាងលើ ព្រឹទ្ធសភា បានបង្កើតគណៈកម្ម-

ការពិសេសចំនួន**០៦** ដូចខាងក្រោម ៖

-គណៈកម្មការពិសេស ទទួលបន្ទុករៀបចំសេចក្តីស្នើបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា

-គណៈកម្មការពិសេស ទទួលបន្ទុករៀបចំសញ្ញាស័ក្តិ និងឯកសណ្ឋានសមាជិកព្រឹទ្ធសភា

-គណៈកម្មការពិសេស ទទួលបន្ទុករៀបចំសេចក្តីស្នើ វិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា

-គណៈកម្មការពិសេស ទទួលបន្ទុកពិនិត្យសិក្សាអំពីការស្នើផ្តល់គ្រឿងឥស្សរិយយស ជូនសមាជិក សមាជិកាព្រឹទ្ធសភា នៅពេលបញ្ចប់នីតិកាលទី១ និងពាក់កណ្តាលនីតិកាលទី២

-គណៈកម្មការពិសេស ទទួលបន្ទុករៀបចំសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាឆ្នាំ១៩៩៩

-គណៈកម្មការពិសេស ទទួលបន្ទុករៀបចំសេចក្តីស្នើច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា ។

## ២.មុខងារតំណាង

ក្នុងការអនុវត្តនូវមុខងារតំណាងនេះ ព្រឹទ្ធសភាបានបើកវេទិកាចំនួន**០៧** ភូមិភាគ ដែលមានតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ ចូលរួមចំនួន**១.០២១**នាក់ ដូចខាងក្រោម ៖

-វេទិកាស្តីពី វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា និងភាពជាតំណាងផលប្រយោជន៍ឃុំ សង្កាត់ នៅខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៧ ដែលមានសមាសភាពចូលរួមសរុបចំនួន**១៦០**នាក់ ក្នុងនោះមានតំណាងក្រុមប្រឹក្សាឃុំ ទូទាំងភូមិភាគទី៤ ចូលរួមចំនួន**៦៦**នាក់ ។

-វេទិកាស្តីពី វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា និងភាពជាតំណាងផលប្រយោជន៍ឃុំ សង្កាត់ នៅខេត្តកោះកុង កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៧

ដែលមានសមាសភាពចូលរួមសរុបចំនួន**២៤៧**នាក់ ក្នុងនោះមានតំណាងក្រុមប្រឹក្សាឃុំ ទូទាំងភូមិភាគទី៧ ចូលរួមចំនួន**៥៥**នាក់ ។

-វេទិកាស្តីពី សិទ្ធិមនុស្ស ការគោរពច្បាប់នៅមូលដ្ឋាន វិមជ្ឈការ វិសហមជ្ឈការ និងភាពជាតំណាងផលប្រយោជន៍ ឃុំ សង្កាត់ នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៧ ដែលមានសមាសភាពចូលរួមសរុបចំនួន**២០៩**នាក់ ក្នុងនោះមាន តំណាងក្រុមប្រឹក្សាសង្កាត់ ទូទាំងភូមិភាគទី១ ចូលរួមចំនួន**៧៦**នាក់ ។

-វេទិកាស្តីពី វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា និងភាពជាតំណាងផលប្រយោជន៍ឃុំ សង្កាត់ នៅខេត្តស្វាយរៀង កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ ដែលមានសមាសភាពចូលរួមសរុបចំនួន**៣៣៧**នាក់ ក្នុងនោះមានតំណាងក្រុមប្រឹក្សាឃុំ ទូទាំងភូមិភាគទី៦ ចូលរួមចំនួន**២១៦**នាក់ ។

-វេទិកាស្តីពី វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា និងភាពជាតំណាងផលប្រយោជន៍ឃុំ សង្កាត់ នៅខេត្តកំពត កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៨ ដែលមានសមាសភាពចូលរួមសរុបចំនួន**២៦៨**នាក់ ក្នុងនោះមានតំណាងក្រុមប្រឹក្សាឃុំ ទូទាំងភូមិភាគទី៥ ចូលរួមចំនួន**១២៧**នាក់ ។

-វេទិកាស្តីពី ការលើកកម្ពស់ផលប្រយោជន៍ឃុំ សង្កាត់ លើការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ នៅឃុំ សង្កាត់ នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ដែលមានសមាសភាពចូលរួមសរុប ចំនួន**២០៤**នាក់ ក្នុងនោះមានតំណាងក្រុមប្រឹក្សាសង្កាត់ ទូទាំងភូមិភាគទី១ ចូលរួមចំនួន**៦៦**នាក់ ។

-វេទិកាស្តីពី វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា និងភាពជាតំណាងផលប្រយោជន៍ឃុំ សង្កាត់ នៅខេត្តកណ្តាល កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៨ ដែលមានសមាសភាពចូលរួមសរុបចំនួន**៣៤៧**នាក់ ក្នុងនោះមានតំណាងក្រុមប្រឹក្សាឃុំ ទូទាំងភូមិភាគទី៣ ចូលរួមចំនួន**១៩៣**នាក់ ។

-វេទិកាស្តីពី វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា និងភាពជាតំណាងផល ប្រយោជន៍ឃុំ នៅខេត្តកំពង់ចាម កាលពីថ្ងៃទី០៣-០៤ខែកុម្ភៈ ឆ្នាំ២០០៩ ដែលមានសមាសភាពចូលរួមសរុបចំនួន**៣២៤**នាក់ ក្នុងនោះមានតំណាងក្រុមប្រឹក្សាឃុំ ទូទាំងភូមិភាគទី២ ចូលរួមចំនួន**២២២**នាក់។

ការរៀបចំវេទិកានេះ សំដៅឆ្ពោះទៅក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីបង្កិតស្ថាប័នព្រឹទ្ធសភាឱ្យទៅជិតថ្នាក់មូលដ្ឋាន និងបង្ហាញឱ្យកាន់តែច្បាស់ នូវភាពជាតំណាងផលប្រយោជន៍ឃុំ សង្កាត់ ក្នុងក្របខ័ណ្ឌភូមិភាគទាំង៨ នៃព្រះរាជាណាចក្រកម្ពុជា ។

វេទិកាទាំងអស់ខាងលើនេះ ដំណើរការទៅបានជោគជ័យ អាស្រ័យដោយមានកិច្ចសហការល្អ រវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជាមួយសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ក្រោមកិច្ចឧបត្ថម្ភគាំទ្រពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ សហគមន៍អឺរ៉ុប មូលនិធិខុនរ៉ាដ អាឌិនណៅអ៊ែរ និងសប្បុរសជននានា។

គិតចាប់តាំងពីពេលព្រឹទ្ធសភាត្រូវបានបង្កើតឡើងមកដល់ពេលនេះ ថ្នាក់ដឹកនាំ គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការជំនាញ សមាជិក សមាជិកាព្រឹទ្ធសភា បានចុះមូលដ្ឋានសាកសួរសុខទុក្ខប្រជាពលរដ្ឋ និងជួយដោះស្រាយបញ្ហាផ្សេងៗ សរុបចំនួន**៩.៨០៤**លើក។

### ៣-មុខងារត្រួតពិនិត្យ

#### ក-គណៈកម្មការជំនាញទាំង៩របស់ព្រឹទ្ធសភា

គណៈកម្មការជំនាញទាំង៩ បានចុះទៅតាមខេត្ត ក្រុង ទូទាំងប្រទេសចំនួន **១៤៣**លើក ដើម្បីពិនិត្យការអនុវត្តច្បាប់ និងគោលនយោបាយផ្សេងៗ លើគ្រប់វិស័យនៅមូលដ្ឋាន។

#### ខ-ក្រុមសមាជិកាព្រឹទ្ធសភា

ក្រុមសមាជិកាព្រឹទ្ធសភា និងគណៈកម្មការនារី នៃអគ្គលេខាធិការដ្ឋាន

ព្រឹទ្ធសភា បានចុះសួរសុខទុក្ខ និងសំណេះសំណាល ជាមួយសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ និងនារីនៅតាមភូមិភាគទាំង៨ចំនួន**៤៧**លើក ។ ទន្ទឹមនឹងនោះ ក្រុមសមាជិកាព្រឹទ្ធសភា បានបើកវេទិកាលើកទី១ ស្តីពី ការលើកកម្ពស់តួនាទីសមាជិកាក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ នៅភូមិភាគទី៧ ខេត្តកោះកុង កាលពីថ្ងៃ១៩-២០ ខែកុម្ភៈ ឆ្នាំ២០០៩ ដែលមានសមាសភាពចូលរួមសរុបចំនួន**១៦៥**នាក់ ក្នុងនោះសមាជិកាក្រុមប្រឹក្សាឃុំ-សង្កាត់ទូទាំងភូមិភាគទី៧ចូលរួមចំនួន**៧៦**នាក់ ។

### ៤_មុខងារព័ត៌មាន

ព្រឹទ្ធសភា បានចាត់បញ្ជូនគណៈប្រតិភូរបស់គណៈកម្មការ និងសមាជិកសមាជិកាទៅបំពេញបេសកកម្ម ស្រាវជ្រាវស្វែងរកព័តិមានទៅតាមការចាំបាច់ ហើយបានផ្តល់ព័តិមានទាំងនោះដល់ព្រឹទ្ធសភា អំពីសភាពការណ៍ សេដ្ឋកិច្ច សង្គមវប្បធម៌ សាសនា បរិស្ថាន និងតម្រូវការរបស់មូលដ្ឋាន ។

### ៥_ការងារទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ

#### ក_ការងារទំនាក់ទំនងសាធារណៈ

ក្នុងរយៈពេល១០ឆ្នាំនេះ ថ្នាក់ដឹកនាំព្រឹទ្ធសភា បានជួបសវនាការជាមួយភ្ញៀវជាតិ អន្តរជាតិ និងបានអញ្ជើញចូលរួមក្នុងពិធីផ្សេងៗ សរុបចំនួន**១.៦១០**លើក ដែលក្នុងនោះបែងចែកដូចខាងក្រោម ÷

-សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា សរុបចំនួន**៩៣២**លើក ។

-សម្តេច **ស៊ីសុវត្ថិ ជីវ័នមុនីរក្ស** អនុប្រធានទី១នៃព្រឹទ្ធសភា សរុបចំនួន**៤៥៤**លើក ។

-ឯកឧត្តម **នេត ខន** អនុប្រធានទី២នៃព្រឹទ្ធសភា សរុបចំនួន**១៧៥**លើក ។

-ឯកឧត្តម **ញឹក ប៊ុនឆៃ** អតីតអនុប្រធានទី២នៃព្រឹទ្ធសភា សរុបចំនួន**២៨**

លើក ។

-ឯកឧត្តម ចៅ ម៉ិនស្រ៊ី អតីតអនុប្រធានទី២នៃព្រឹទ្ធសភា សរុបចំនួន**២១** លើក ។

## ខ-កិច្ចសហប្រតិបត្តិការអន្តរជាតិ

ចាប់តាំងពីឆ្នាំ១៩៩៩មក ព្រឹទ្ធសភា បានយកការងារទំនាក់ទំនងអន្តរជាតិជាកម្លាំងស្នូល ក្នុងការអភិវឌ្ឍស្ថាប័ន ។ ជាក់ស្តែង ព្រឹទ្ធសភាបានបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយសភាប្រទេសជាមិត្ត តាមរយៈការបង្កើតក្រុមមិត្តភាពរវាងព្រឹទ្ធសភាកម្ពុជា ជាមួយសភាបណ្តាប្រទេសនានា ព្រមទាំងសមាជិកភាពក្នុងសហភាពអន្តរសភា (IPU) អង្គការអន្តរសភាអាស៊ាន (AIPA) សមាគមសភានៃប្រទេសប្រើភាសាបារាំង (APF) ។ល ។ លើសពីនេះ ព្រឹទ្ធសភាបានពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងភាពជាដៃគូយូរអង្វែងជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) មូលនិធិខុនរ៉ាដអាឌិនណៅអ៊ែរ (KAF) ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិកាណាដា (CIDA) តាមរយៈគម្រោងគាំទ្រនីតិប្បញ្ញត្តិកម្ពុជា កាណាដា (CCLSP) មូលនិធិអាស៊ី និងដៃគូអន្តរជាតិផ្សេងទៀត ។ ជាពិសេសរដ្ឋាភិបាលជប៉ុន ចិន វៀតណាម ព្រឹទ្ធសភាបារាំង កាណាដា អូស្ត្រាលី និងរដ្ឋសភា នៃសាធារណរដ្ឋកូរ៉េ បានរួមចំណែកយ៉ាងសកម្មជួយដល់ព្រឹទ្ធសភាកម្ពុជា ។

## គ-ការផ្លាស់ប្តូរគណៈប្រតិភូជាន់ខ្ពស់សភា

គណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភាកម្ពុជា ដឹកនាំដោយសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា បានអញ្ជើញ និងយាងទៅបំពេញទស្សនកិច្ចផ្លូវការនៅរាជាណាចក្រជប៉ុន សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដើម្បីរឹតចំណងសាមគ្គីភាព កិច្ចសហប្រតិបត្តិការល្អលើគ្រប់វិស័យ រវាងស្ថាប័នសភា និងប្រជាជននៃប្រទេសទាំងនានា ឱ្យកាន់តែជិតស្និទ្ធ និងខ្លាំងក្លាថែមទៀត ។

ទន្ទឹមនឹងនេះ មានគណៈប្រតិភូជាន់ខ្ពស់សភា នៃប្រទេសនានា បានមកបំពេញទស្សនកិច្ចផ្លូវការនៅព្រឹទ្ធសភា ដូចជា គណៈប្រតិភូដឹកនាំដោយប្រធានព្រឹទ្ធសភាបារាំង ប្រធានព្រឹទ្ធសភាប៊ែលហ្ស៊ិក ប្រធានព្រឹទ្ធសភាអូស្ត្រាលី ប្រធានព្រឹទ្ធសភាកាណាដា និងប្រធានគណៈកម្មាធិការជាតិសភាប្រឹក្សានយោបាយប្រជាជនចិន ។

ម្យ៉ាងទៀត ព្រឹទ្ធសភាបានបញ្ជូនគណៈប្រតិភូជាច្រើនក្រុម ទៅធ្វើទស្សនកិច្ចផ្លូវការ ទស្សនកិច្ចសិក្សាដកពិសោធការងារសភា ចូលរួមកិច្ចប្រជុំ អង្គសន្និសីទ សិក្ខាសាលានៅប្រទេសនានា ចំនួន**២១១**រូប និងបានទទួលគណៈប្រតិភូបរទេស មកបំពេញទស្សនកិច្ច និងចូលរួមកិច្ចប្រជុំនៅព្រះរាជាណាចក្រកម្ពុជា ចំនួន**៤១២**លើក ។

## ឃ. លទ្ធផលនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ

ចាប់តាំងពីថ្ងៃបង្កើត ស្ថាប័នព្រឹទ្ធសភា នាឆ្នាំ១៩៩៩ មកទល់ពេលនេះ ព្រឹទ្ធសភាបានទទួលជំនួយជាបន្តបន្ទាប់ ពីរដ្ឋាភិបាល និងសភានៃបណ្តាប្រទេសជាមិត្ត សម្រាប់អភិវឌ្ឍស្ថាប័ន មានទឹកប្រាក់សរុបចំនួន**៤.៨០៤.១២៣,១៦** ដុល្លារអាមេរិក ជាអាទិ៍មាន ÷

-រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន បានផ្តល់ជំនួយសម្រាប់សាងសង់សាលប្រជុំពេញអង្គព្រឹទ្ធសភា អគារបណ្ណាល័យ និងអគារការិយាល័យរបស់សមាជិកព្រឹទ្ធសភា ស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធក្នុងព្រឹទ្ធសភា កុំព្យូទ័រ និងរថយន្ត មានទឹកប្រាក់សរុបចំនួន**៣.២៤២.៩២១** ដុល្លារអាមេរិក ។

-រាជរដ្ឋាភិបាលជប៉ុន បានផ្តល់ជំនួយសម្រាប់ជួសជុលអគារចាស់ៗ សម្ភារការិយាល័យ គ្រឿងបរិក្ខារ និងបំពាក់ S tudio ដល់ព្រឹទ្ធសភា មានទឹកប្រាក់សរុបចំនួន**១.៣២៥.៧០២,១៦** ដុល្លារអាមេរិក ។

-រដ្ឋសភា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានផ្តល់ជំនួយជាសម្ភារការិយាល័យ និងកម្រាលព្រំ មានទឹកប្រាក់សរុបចំនួន**១៥៥.000** ដុល្លារ

អាមេរិក ។

-រដ្ឋសភា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ បានផ្តល់កុំព្យូទ័រដែលមានទឹកប្រាក់ចំនួន**២៨.៦០០** ដុល្លារអាមេរិក ព្រមទាំងទូដាក់ឯកសារ និងរថយន្ត**០១**គ្រឿង ។

-ព្រឹទ្ធសភា រដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង និងសមាគមសភានៃប្រទេសប្រើភាសាបារាំង បានផ្តល់កុំព្យូទ័រ ព្រីនទ័រ និងម៉ាស៊ីន Scanner មានទឹកប្រាក់សរុបចំនួន**៣១.៩០០** ដុល្លារអាមេរិក ។

-រដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេដារុយសាឡឹម បានផ្តល់សម្ភារគិតជាទឹកប្រាក់សរុបចំនួន**២០.០០០** ដុល្លារអាមេរិក ។

-សាធារណរដ្ឋឥណ្ឌូនេស៊ី បានបំពាក់គ្រឿងសង្ហារិម ដល់បន្ទប់ទទួលភ្ញៀវធំរបស់ព្រឹទ្ធសភា ។

ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ ព្រឹទ្ធសភាបានរៀបចំវេទិកា សិក្ខាសាលា កិច្ចប្រជុំ កិច្ចពិភាក្សាតុមូល ចំនួន **១០៥**លើក ដែលមានប្រធានបទពាក់ព័ន្ធដល់កិច្ចដំណើរការ និងការអភិវឌ្ឍស្ថាប័នព្រឹទ្ធសភា ។

# រូបភាព
# ស្តីពីសកម្មភាពរបស់ថ្នាក់ដឹកនាំ
# និងសមាជិក សមាជិកា
# ព្រឹទ្ធសភា

# កិច្ចប្រជុំពេញអង្គ



# កិច្ចប្រជុំគណៈកម្មាធិការអេចអាំង្គ្លេយ៍

# កិច្ចប្រជុំរបស់គណៈកម្មការជំនាញក្នុងការពិភាក្សាច្បាប់

# កិច្ចប្រជុំរបស់គណៈកម្មការជំនាញក្នុងការពិភាក្សាច្បាប់

## កិច្ចប្រជុំរបស់គណៈកម្មការជំនាញក្នុងការពិភាក្សាច្បាប់

LEVEL/DECENTRALIZATION,DECONCENTRATION
AND THE REPRESENTATION OF COMMUNAL INTE
UNDER THE NOBLE PRESIDENCY OF SAMDECH AK
THOMMAK POTHISAL CHEA SIM, ACTING HEAD
OF THE KINGDOM OF CAMBODIA
DECEMBER 07, 2007

វេទិកាស្តីពី "វិមជ្ឈការ វិសហមជ្ឈការ និងការជាតំណាងផលប្រយោជន៍ឃុំ-សង្កាត់" នៅភូមិភាគទី៣

## វេទិកាស្តីពី "វិមជ្ឈការ វិសហមជ្ឈការ និងភាពជាតំណាងផលប្រយោជន៍ឃុំ សង្កាត់" នៅភូមិភាគទី៤

Senate-NLC/S Forum on
Decentralization, Deconcentration
in Cambodia and Representing
Commune/Sangkat Interests
Koh Kong, Province, 25 September 2007

វេទិកាស្តីពី "វិមជ្ឈការ វិសហមជ្ឈការ និងតាងភាពតំណាងផលប្រយោជន៍ឃុំ-សង្កាត់" នៅភូមិភាគទី៥

Senate-NLC/S Forum
on
"Decentralization, Deconcentration in
Cambodia and Representing

## សកម្មភាពចុះមូលដ្ឋានរបស់គណៈកម្មការជំនាញ

# សកម្មភាពចុះមូលដ្ឋានរបស់គណៈកម្មការជំនាញ

# សកម្មភាពចុះមូលដ្ឋានរបស់គណៈកម្មការជំនាញ

# សកម្មភាពសិក្ខាសាលា

ពិធីសំណេះសំណាលរវាងក្រុមសមាជិកាព្រឹទ្ធសភា ជាមួយសមាជិកាក្រុមប្រឹក្សាឃុំសង្កាត់ខេត្តកណ្ដាល

សម្តេចប្រធានព្រឹទ្ធសភា ជួបជាមួយប្រធានព្រឹទ្ធសភាកាណាដា

សម្តេចប្រធានព្រឹទ្ធសភា ជួបជាមួយប្រធានព្រឹទ្ធសភាបារាំង

សម្តេចប្រធានព្រឹទ្ធសភា ជួបជាមួយប្រធានព្រឹទ្ធសភាបែលហ្ស៊ិក

## សម្តេចប្រធានព្រឹទ្ធសភា ជួបជាមួយប្រធានព្រឹទ្ធសភាអូស្ត្រាលី

## សម្តេចប្រធានព្រឹទ្ធសភា ជួបជាមួយប្រធានគណៈកម្មាធិការជាតិ សភាប្រឹក្សានយោបាយប្រជាជនចិន

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំ
គណៈប្រតិភូចូលជួបសន្ទនាការជាមួយឯកឧត្តម Wu BANGGUA ប្រធានសភាប្រជាជាតិចិន



សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈ
ប្រតិភូចូលជួបសន្ទនាការជាមួយឯកឧត្តម Jia QINGLIN ប្រធានគណៈកម្មាធិការជាតិសភាប្រឹក្សា
នយោបាយប្រជាជនចិន

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំ
គណៈប្រតិភូចូលជួបសន្ទនាការជាមួយឯកឧត្តម Nong DUC MANH អគ្គលេខាធិការបក្ស
កុំមុយនីស្តវៀតណាម

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំ
គណៈប្រតិភូចូលជួបសន្ទនាការជាមួយឯកឧត្តម Nguyen PHU TRONG ប្រធានរដ្ឋសភាវៀតណាម

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានទទួលគ្រឿង
ឥស្សរិយយស "មាស" ខ្ពស់បំផុតពីឯកឧត្តម ជុម ម៉ាលី សៃញ៉ាសន អគ្គលេខាធិការ នៃគណៈកម្មា
ធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍ឡាវ និងជាប្រធានរដ្ឋ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំ
គណៈប្រតិភូចូលជួបសមនាការជាមួយឯកឧត្តម ថងស៊ីង ថាំម៉ាវង្ស ប្រធានរដ្ឋសភា នៃសាធារណរដ្ឋ
ប្រជាធិបតេយ្យប្រជាមានិតឡាវ

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញចុះជួប និងសំណេះសំណាលជាមួយប្រជាពលរដ្ឋ នៅតាមខេត្ត ក្រុងនានា**

សម្តេច ស៊ីសុវត្ថិ ជីវ័នមុនីរក្ស អនុប្រធានទី១ព្រឹទ្ធសភា បានយាងជាព្រះអធិបតីក្នុងពិធីសម្ពោធ
ផ្លូវក្រាលឥដ្ឋការ៉ូ ក្នុងបរិវេណវត្តព្រះថ្វាយពិសី ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្តាល

ឯកឧត្តម ទេព ងន អនុប្រធានទី២ព្រឹទ្ធសភា អញ្ជើញចុះជួប និងសំណេះសំណាលជាមួយ
ប្រជាពលរដ្ឋ នៅតាមខេត្ត ក្រុងនានា

## ៦_សកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានតួនាទីជាសេនាធិការផ្ទាល់ឱ្យព្រឹទ្ធសភា រ៉ាប់រងរាល់កិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ សន្តិសុខ និងសេវាទាំងឡាយរបស់ព្រឹទ្ធសភា ព្រមទាំងទំនាក់ទំនងផ្សេងៗនៅក្នុង និងក្រៅស្ថាប័ន ។

### ក_គោលការណ៍គ្រប់គ្រងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានយន្តការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ បើកចំហ និងមានតម្លាភាព ។ ជាទូទៅ ការរៀបចំលិខិតបទដ្ឋាន គោលនយោបាយផ្សេងៗ សម្រាប់ការដឹកនាំ គ្រប់គ្រង ត្រូវបានប្រគល់ជូនគណៈកម្មការ ដែលមានសមាសភាពចម្រុះ មកពីគ្រប់អង្គភាពចំណុះ ហើយជាមន្ត្រីរាជការ ដែលមានបទពិសោធន៍ក្នុងការងារ ។

អនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិ បទប្បញ្ញត្តិបន្ទាប់មួយចំនួនត្រូវបានរៀបចំឡើង ដើម្បីបម្រើសេចក្តីត្រូវការចាំបាច់ក្នុងការដឹកនាំ និងគ្រប់គ្រងធនធានមនុស្ស និងការគិតគូរពីផលប្រយោជន៍មន្ត្រីរាជការ ដើម្បីធានាបាន នូវការអភិវឌ្ឍស្ថាប័នបានជាប់លាប់ យូរអង្វែង ព្រមទាំងធ្វើសមាហរណកម្មមន្ត្រីរាជការពីក្របខ័ណ្ឌចាស់ ចូលក្របខ័ណ្ឌថ្មី ។

ក្នុងការអភិវឌ្ឍស្ថាប័ន អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានកសាងឯកសារជាមូលដ្ឋានដូចតទៅ ៖

-ផែនការយុទ្ធសាស្ត្រ៥ឆ្នាំ (២០០៣-២០០៨) ដែលមាន៥គោលដៅយុទ្ធសាស្ត្រគឺ ៖

+ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

+រចនាសម្ព័ន្ធ ប្រព័ន្ធគោលនយោបាយ និងនីតិវិធីនៃការគ្រប់គ្រង

+ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

+ការផ្សព្វផ្សាយព័ត៌មាន

+ទំនាក់ទំនងជាមួយស្ថាប័នជាតិ និងអន្តរជាតិ ។

-ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជារយៈពេល១០ឆ្នាំ (២០០៨-២០១៨) ដែលចែកចេញជា :

១-ផែនការសកម្មភាពរយៈពេលខ្លី (២០០៨-២០០៩) ដែលផ្តោតលើ ÷

+ការពង្រឹងតួនាទីរបស់ព្រឹទ្ធសភា

+ការពង្រឹងពង្រីកធនធានមនុស្ស និងការអភិវឌ្ឍស្ថាប័ន។

២-ផែនការសកម្មភាពរយៈពេលមធ្យម (២០១០-២០១៣) ដែលផ្តោតលើ ÷

+ការបណ្តុះបណ្តាលសម្រាប់សមាជិកព្រឹទ្ធសភាថ្មី

+ការពិនិត្យមើលរបៀបរបបពិនិត្យអត្ថបទច្បាប់ ឬសេចក្តីស្នើច្បាប់

+ការចូលរួមរបស់សភានៅក្នុងការរៀបចំសេចក្តីព្រាងច្បាប់តាំងពីដំណាក់កាលដំបូង

+ផែនការយុទ្ធសាស្ត្រថ្នាក់គណៈកម្មការជំនាញ

+ការពង្រឹងតួនាទីរៀបចំ និងតាមដានថវិកាព្រមទាំងការតាមដានការវិវឌ្ឍសេដ្ឋកិច្ច សង្គម និងវប្បធម៌

+ការពង្រីកទំនាក់ទំនងសាធារណៈ

+ភាពជាតំណាងរបស់ព្រឹទ្ធសភា

+កម្មវិធីបណ្តុះបណ្តាលទូទៅ ។

៣-ផែនការសកម្មភាពរយៈពេលវែង(២០១៤-២០១៨) ដែលផ្តោតលើ ÷

+ការបង្កើតមជ្ឈមណ្ឌលសភា

+ការបន្តពង្រឹងតួនាទីរៀបចំ និងតាមដានថវិកា និងការវិវឌ្ឍសេដ្ឋកិច្ច សង្គម និងវប្បធម៌

+ការអភិវឌ្ឍសមត្ថភាពសវនកម្មរបស់ព្រឹទ្ធសភា

+ការធានាសមត្ថភាពធ្វើជាតំណាងរបស់សមាជិកព្រឹទ្ធសភា។

ជាមួយនេះដែរអង្គភាពទាំងអស់របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានកសាងនូវផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ (២០០៨-២០១២) ដែលឆ្លើយតបទៅនឹងក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជារយៈពេល១០ឆ្នាំ (២០០៨-២០១៨)។

ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការជាមួយរដ្ឋសភា អគ្គលេខាធិការដ្ឋាននៃសភាទាំង២ (ព្រឹទ្ធសភា និងរដ្ឋសភា) បានកសាងនូវក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពសភាកម្ពុជារយៈពេល១០ឆ្នាំ (២០០៨-២០១៨) ដែលជាត្រីវិស័យនៃដំណើរអភិវឌ្ឍន៍ព្រឹទ្ធសភា និងរដ្ឋសភាកម្ពុជា។

ក្រោមកិច្ចសហប្រតិបត្តិការជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានសិក្សា និងកសាងប្លង់មេមួយចំនួនដើម្បីអភិវឌ្ឍស្ថាប័នដូចមានខាងក្រោម ៖

+ប្លង់មេសម្រាប់ការអភិវឌ្ឍសមត្ថភាពខាងច្បាប់

+ប្លង់មេសម្រាប់ការអភិវឌ្ឍបណ្ណាល័យ និងបណ្ណសារ

+ប្លង់មេសម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន ( IT )

+ប្លង់មេសម្រាប់ការអភិវឌ្ឍការប្រាស្រ័យឆ្លើយឆ្លង

+ប្លង់មេសម្រាប់ការបណ្តុះបណ្តាលធនធានមនុស្ស។

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានរៀបចំ និងអនុវត្តនូវសេចក្តីសម្រេចរួម (ព្រឹទ្ធសភា រដ្ឋសភា និងក្រុមប្រឹក្សាធម្មនុញ្ញ) ចំនួន០៦ និងគោលនយោបាយចំនួន០៨ ដូចខាងក្រោម ៖

**១-សេចក្តីសម្រេចរួម**

-សេចក្តីសម្រេច លេខ : ០១៧/០៦០៣/ពស/សរ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីការផ្ទេរអ្នករាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទៅក្នុង

ក្របខ័ណ្ឌមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ

-សេចក្តីសម្រេច លេខ : ០១ ព.រ.ក ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីបៀវត្សរ៍មូលដ្ឋាន និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ

-សេចក្តីសម្រេច លេខ : ០២ ព.រ.ក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សរ៍ មូលដ្ឋានរបស់មន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ

-សេចក្តីសម្រេច លេខ : ០០៣ ព.រ.ក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកែប្រែតម្លៃឯកតានៃសន្ទស្សន៍ បៀវត្សរ៍មូលដ្ឋានរបស់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ

-សេចក្តីសម្រេច លេខ : ០០៤ ព.រ.ក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកែប្រែប្រាក់វិភាជន៍គ្រួសារប្រចាំខែ របស់មន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ

-សេចក្តីសម្រេច លេខ : ០០៥ ព.រ.ក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈសម្រាប់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ ។

**២-គោលនយោបាយ**

-គោលនយោបាយស្តីពី ការជ្រើសរើសអ្នករាជការឱ្យចូលធ្វើការ

-គោលនយោបាយស្តីពី ការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត

-គោលនយោបាយស្តីពី ការពិពណ៌នាការងារ

-គោលនយោបាយស្តីពី ការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្ស

-គោលនយោបាយស្តីពី ការជំរុញ និងលើកទឹកចិត្តដល់អ្នករាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-គោលនយោបាយចំពោះស្ត្រីក្នុងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-គោលនយោបាយស្តីពី ការតែងតាំងអ្នករាជការឱ្យកាន់មុខតំណែង គ្រប់គ្រងនៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-គោលនយោបាយស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ សម្រាប់អ្នករាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

បន្ថែមលើនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បាននិងកំពុងរៀបចំតាក់តែងបន្ត នូវសេចក្តីព្រាងគោលនយោបាយ និងព្រឹត្តិបត្រវាយតម្លៃ មួយចំនួនទៀតមាន ÷

-ព្រឹត្តិបត្រវាយតម្លៃបុគ្គលិកជាប់កិច្ចសន្យា

-គោលនយោបាយស្តីពី ការគ្រប់គ្រងអ្នកហាត់ការឱ្យមានប្រសិទ្ធភាព

-ព្រឹត្តិបត្រវាយតម្លៃអ្នករាជការឱ្យកាន់មុខតំណែងទទួលខុសត្រូវ

-គោលនយោបាយស្តីពី ការដោះស្រាយវិវាទ ក្នុងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-គោលនយោបាយស្តីពី ការដាក់អ្នករាជការឱ្យនៅទំនេរគ្មានប្រាក់បៀវត្សរ៍

-គោលនយោបាយស្តីពី ការដាក់អ្នករាជការឱ្យនៅក្រៅក្របខ័ណ្ឌដើម ។

ជាមួយនេះដែរ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានកសាង និងធ្វើបច្ចុប្បន្នភាពតួនាទី ភារកិច្ច និងសមត្ថកិច្ច របស់អង្គភាពចំណុះ និងកែសម្រួលរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន ដើម្បីធានាបាននូវប្រសិទ្ធភាពការងារ ការទទួលខុសត្រូវច្បាស់លាស់ និងនិរន្តរភាពការងារ ។

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានបង្កើតគណៈកម្មការផ្ទៃក្នុងជាបន្តបន្ទាប់ឱ្យទទួលភារកិច្ច ផ្សេងៗពីគ្នាដូចខាងក្រោម ÷

-គណៈកម្មការវាយតម្លៃមន្ត្រីរាជការដំឡើងកាំបៀវត្សរ៍

-គណៈកម្មការត្រួតពិនិត្យខ្លឹមសារ ឧបសម្ព័ន្ធសេចក្តីសម្រេច ស្តីពីរចនាសម្ព័ន្ធគ្រប់គ្រងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-គណៈកម្មការរៀបចំតាក់តែងពិនិត្យអត្ថន័យខ្លឹមសារ ប្រទីបព្រឹទ្ធសភា

-គណៈកម្មការរៀបចំពិធីបុណ្យឆ្លងសហស្សវត្សរ៍

-គណៈកម្មការរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីរាជការ

-គណៈកម្មការពិនិត្យលទ្ធភាពបញ្ចូលបុគ្គលិកអណ្តែត ក្នុងក្របខ័ណ្ឌពេញសិទ្ធិ

-គណៈកម្មការសារពើភណ្ឌ

-គណៈកម្មការវាយតម្លៃធ្វើពិសោធន៍ចង់ដឹងបេក្ខជន

-គណៈកម្មការរៀបចំសេចក្តីស្នើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ

-គណៈកម្មការដំឡើងកាំប្រៀវត្សមន្ត្រីរាជការ ឆ្នាំ២០០១

-គណៈកម្មការគ្រប់គ្រងវគ្គបណ្តុះបណ្តាលជំនាញកុំព្យូទ័រ

-គណៈកម្មការជ្រើសរើសមន្ត្រីរាជការ ទៅរៀននៅសាលាភូមិន្ទរដ្ឋបាល

-គណៈកម្មការរៀបចំផែនការយុទ្ធសាស្ត្រ

-គណៈកម្មការជ្រើសរើសមន្ត្រីទៅរៀននៅ នូវែលហ្សេឡង់

-គណៈកម្មការកែសម្រួលបទបញ្ជាផ្ទៃក្នុងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-គណៈកម្មការនារី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-គណៈកម្មការវាយតម្លៃតាំងស៊ប់ក្នុងក្របខ័ណ្ឌពេញសិទ្ធិមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-គណៈកម្មការរៀបចំគម្រោងប្រាក់បំណាច់មុខងារមន្ត្រីរាជការ

-គណៈកម្មការបណ្តុះបណ្តាល ធនធានមនុស្ស

-គណៈកម្មការសម្រាប់ផ្ទេរអ្នករាជការ ទៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ

-គណៈកម្មការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងរបស់អគ្គលេខាធិការដ្ឋាន

ព្រឹទ្ធសភា

-គណៈកម្មការធនធានមនុស្សរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-គណៈកម្មការស្រាវជ្រាវបទបញ្ជាផ្ទៃក្នុង

-គណៈកម្មការរៀបចំសញ្ញាសក្តិ និងឯកសណ្ឋាន មន្ត្រីរាជការ នៃក្រុម នីតិបញ្ញត្តិ

-គណៈកម្មការពិនិត្យបញ្ហាដំឡើងកាំបៀវត្សរ៍

-គណៈកម្មការបូកសរុប និងតាក់តែងឯកសារ ស្នាដៃព្រឹទ្ធសភា នីតិកាលទី១

-គណៈកម្មការរៀបចំសេចក្តីព្រាងគោលការណ៍អំពីការសរសើរ ជូនរង្វាន់ គ្រឿងឥស្សរិយយសដល់មន្ត្រីរាជការ

-គណៈកម្មការត្រួតពិនិត្យ និងសិក្សាលើការអនុវត្តរចនាសម្ព័ន្ធថ្មី របស់ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-គណៈកម្មការសិក្សាអំពីដំណើរការប្រឡង ជ្រើសរើសអ្នករាជការក្របខ័ណ្ឌ

-គណៈកម្មការប្រឡងប្តូរក្របខ័ណ្ឌអ្នករាជការ

-គណៈកម្មការសិក្សាអំពីការរៀបចំអគ្គនាយកដ្ឋាននៃអគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា។

### ខ.ការបណ្តុះបណ្តាលធនធានមនុស្សក្នុង និងក្រៅប្រទេស

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបង្កើនសមត្ថភាពមន្ត្រីរាជការដោយផ្អែកលើជំនួយពីដៃគូជាតិ និងអន្តរជាតិ។

ចាប់តាំងពីឆ្នាំ១៩៩៩ មកដល់បច្ចុប្បន្ននេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីរាជការសរុប ចំនួន២៥៨វគ្គ ទាំងក្នុង និងក្រៅប្រទេស។

#### ១.ការបណ្តុះបណ្តាលក្នុងប្រទេស

ការបណ្តុះបណ្តាលនៅក្នុងប្រទេស មានគោលបំណងពង្រឹងសមត្ថភាព

ជំនាញផ្នែករដ្ឋបាល ស្រាវជ្រាវសេដ្ឋកិច្ច សង្គម សិទ្ធិមនុស្ស គ្រប់គ្រងបណ្ណាល័យ ជាវលេខខ្មែរ លេខាធិការ សារព័ត៌មាន ទ្រឹស្តីនៃការព្រាង និងតាក់តែងច្បាប់ វិភាគច្បាប់ ច្បាប់អន្តរជាតិ ព័ត៌មានវិទ្យា និងភាសាបរទេស ។ល។ ចំនួន២៤៨វគ្គ។

| ឆ្នាំ | ១៩៩៩ | ២០០០ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|---|---|---|---|---|---|
| មន្ត្រី | ៣៧ | ៨១ | ២០០ | ៣៤១ | ៣៧៩ | ១.០៦៩ | ៥០៥ | ៨៨២ | ៣៤៧ | ៨៧៤ |

### ២. ការបណ្តុះបណ្តាលនៅក្រៅប្រទេស

ចាប់ពីឆ្នាំ១៩៩៩មក អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមន្ត្រីរាជការចំនួន៩០នាក់ ឱ្យទៅបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សានៅប្រទេសសិង្ហបុរី បារាំង កាណាដា អ៊ីតាលី នូវែលហ្សេឡង់ ជប៉ុន អូស្ត្រាលី ថៃ ស៊ុយអែត គុយបា ហ្វីលីពីន វៀតណាម ចិន និងឡាវ ។ល។

| ឆ្នាំ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|---|---|---|---|
| មន្ត្រី | ០១ | ០២ | ១០ | ១១ | ០៤ | ០៥ | ៣០ | ២៧ |

### គ. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់ស្ថាប័នព្រឹទ្ធសភា

ចាប់តាំងពីឆ្នាំ១៩៩៩មក ព្រឹទ្ធសភាបានជួសជុល និងកែលម្អនូវអគារ បណ្តាញផ្លូវថ្នល់ សួនច្បារ ខ្លោងទ្វារ រៀបចំប្រព័ន្ធទឹកស្អាត និងប្រព័ន្ធលូបង្ហូរទឹក ប្រព័ន្ធអគ្គិសនីក្នុងបរិវេណស្ថាប័ន។ ជាពិសេសបានកសាងបន្ថែមនូវសាលប្រជុំព្រឹទ្ធសភា បណ្ណាល័យ០១ខ្នង និងអគារចំនួន០៣ខ្នង មាន៧៥បន្ទប់ មាន Studio ចំនួន០១ មានបំពាក់ដោយសម្ភារសមរម្យ សម្រាប់បម្រើការងារ ហើយនៅពេលខាងមុខនេះ រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន នឹងជួយជួសជុលអគារ០៤ខ្នង និងកសាងអគារថ្មី ចំនួន០៥ខ្នងទៀត។

# រូបភាព
# ស្តីពីសកម្មភាពរបស់
# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

# ពិធីចុះហត្ថលេខាជាមួយដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ



ពិធីចុះហត្ថលេខាជាមួយអគ្គលេខាធិការ[illegible]អាស៊ី

Opening Training Course
on
"Legal Research and Analysis Skills" Part II
for Staff of Secretariat General of the Senate

ពិធីប្រគល់-ទទួលអំណោយ
CÉRÉMONIE DE REMISE
AU SÉNAT DU ROYAUME DU
LE 14 DÉCEMBRE 2007

នៃព្រះរាជាណាចក្រកម្ពុជា
ភ្នំពេញ,ថ្ងៃទី១៣ វិច្ឆិកា ឆ្នាំ២០០៨
of the Republic of
Phnom Penh, 13

## ការប្រឡងជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការងារក្នុងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា ជួបជាមួយឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាហ្វីលីពីន

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា ជួបជាមួយឯកឧត្តមអគ្គលេខាធិការសភាកូរ៉េ

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា ជួបជាមួយឯកឧត្តមអគ្គលេខាធិការរដ្ឋសភាអាហ្វ្រិកខាងត្បូង

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា ជួបជាមួយឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាអ៊ីតាលី

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា ជួបជាមួយឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាថៃ

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា ជួបជាមួយឯកឧត្តមអគ្គលេខាធិការសភាស៊ុយអែត

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា អញ្ជើញចូលរួមកិច្ចប្រជុំសមាគមអគ្គលេខាធិការសភា នៅទីក្រុងហ្សឺណែវ
នៃសហព័ន្ធស្វីស ហើយឯកឧត្តមបានជាប់ឆ្នោតជាសមាជិកគណៈកម្មាធិការប្រតិបត្តិ
របស់សមាគមអគ្គលេខា_ធិការសភាពិភពលោក

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា ជួបជាមួយព្រឹទ្ធសភាបារាំង

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា ជួបជាមួយលោកស្រីប្រធានកម្មវិធីណូរីយ៉ា

## III-ចក្ខុវិស័យរបស់ព្រឹទ្ធសភារយៈពេល១០ឆ្នាំ

ការពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា គឺជាវិភាគទានមួយដ៏សំខាន់សម្រាប់ធ្វើឱ្យប្រទេសជាតិទទួលជោគជ័យក្នុងការពង្រឹង ពង្រីកលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការសម្រេចបាននូវសមាហរណកម្ម ទៅក្នុងក្របខ័ណ្ឌតំបន់ និងអន្តរជាតិ ។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ ÷

-ព្រឹទ្ធសភា ត្រូវដំណើរការតាមស្តង់ដារការងារនៃសភាប្រជាធិបតេយ្យ និងជាដៃគូដ៏ល្អជាមួយសភាប្រជាធិបតេយ្យ ក្នុងតំបន់ និងលើពិភពលោក ។

-ព្រឹទ្ធសភា ត្រូវបំពេញបាននូវតួនាទីដ៏ចម្បងជាតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេស និងជាកម្លាំងចលករ ដើម្បីធានាជោគជ័យ ក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការរបស់រដ្ឋ និងការអភិវឌ្ឍឃុំ សង្កាត់លើគ្រប់វិស័យ ។

-សមាជិកព្រឹទ្ធសភា ត្រូវសម្រេចឱ្យបាននូវមុខងារនីតិកម្ម មុខងារតំណាង និងមុខងារត្រួតពិនិត្យ ។

-គណៈកម្មការជំនាញព្រឹទ្ធសភា ត្រូវសម្រេចឱ្យបានមុខងារនីតិកម្ម មុខងារត្រួតពិនិត្យ និងមុខងារព័ត៌មាន ក្នុងឋានៈជា កូនព្រឹទ្ធសភាពិតប្រាកដ ។

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវមានសមត្ថភាពផ្តល់សេវាពេញលេញលើគ្រប់វិស័យ និងគ្រប់ជំនាញជូនស្ថាប័ន គណៈកម្មការជំនាញទាំង៩ និងសមាជិកព្រឹទ្ធសភា តាមប្រព័ន្ធរដ្ឋបាលនៃសភាទំនើប ហើយបំពាក់ដោយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទំនើប ។

-មន្ត្រីរាជការបម្រើការងារក្នុងអគ្គលេខាធិការដ្ឋាន ត្រូវមានចំណេះដឹងខ្ពស់ ជំនាញគ្រប់គ្រាន់ និងសមត្ថភាពភាសាខ្ពស់ ដែលអាចផ្តល់សេវាចាំបាច់ ប្រកបដោយគុណភាព និងប្រសិទ្ធភាព ។

ដូចនេះ ព្រឹទ្ធសភាត្រូវមានយន្តការប្រកបដោយសក្តានុពលជាសេនាធិការ

ដោយខិតខំបង្កើតឱ្យបាននូវមជ្ឈមណ្ឌលច្បាប់ មជ្ឈមណ្ឌលព័ត៌មាន មជ្ឈណ្ឌល រៀបចំ និងតាមដានថវិកា មជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន បណ្ណាល័យទំនើប មជ្ឈមណ្ឌលភូមិភាគ និងមជ្ឈមណ្ឌលសភា។

## សេចក្តីសន្និដ្ឋាន

ចាប់តាំងពីនីតិកាលទី១ រហូតមកដល់បច្ចុប្បន្ននេះ ព្រឹទ្ធសភា ពិតជាបានរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេសជាតិ លើគ្រប់វិស័យប្រកបដោយវិចារណញ្ញាណ និងការទទួលខុសត្រូវខ្ពស់ ព្រមទាំងបានចូលរួមយ៉ាងសកម្មក្នុងការពង្រឹងពង្រីកអភិបាលកិច្ចល្អ នីតិរដ្ឋ និងការអនុវត្តលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន។

ក្នុងរយៈពេល១០ឆ្នាំនេះ ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនក្នុងនាមជាស្ថាប័ននីតិប្បញ្ញត្តិ ដែលកាន់តែមានភាពចាស់ទុំ បានទទួលលទ្ធផលវិជ្ជមានក្នុងមុខងារទាំងពាររបស់ខ្លួន។ ជាពិសេសក្នុងនាមជាតំណាងឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ព្រឹទ្ធសភាបានរួមចំណែកយ៉ាងសកម្មក្នុងការជំរុញការអនុវត្តនយោបាយវិមជ្ឈការ វិសហមជ្ឈការនៅកម្ពុជា ឱ្យមានសន្ទុះរីកចម្រើនជាលំដាប់។

លទ្ធផលជាវិជ្ជមានខាងលើនេះ ធ្វើឱ្យស្ថាប័នព្រឹទ្ធសភា មានមុខមាត់ថ្មីមានកិត្តិសព្ទ មានការទទួលស្គាល់ និងមានឋានៈដ៏ស័ក្តិសម ទាំងនៅក្នុងតំបន់ និងលើឆាកអន្តរជាតិ ហើយបានក្លាយជាស្ថាប័នមួយដែលមិនអាចខ្វះបាន នៅក្នុងការជំរុញឱ្យព្រះរាជាណាចក្រកម្ពុជា ក្លាយជានីតិរដ្ឋដ៏ពិតប្រាកដ។

ផ្អែកលើមូលដ្ឋាន នៃលទ្ធផលដែលសម្រេចបានក្នុងរយៈពេល១០ឆ្នាំកន្លងមកនេះ ព្រឹទ្ធសភាសង្ឃឹមថា នាពេលអនាគត នឹងអាចបំពេញបានគ្រប់ជ្រុងជ្រោយ និងកាន់តែពេញលេញថែមទៀត ដោយការទទួលខុសត្រូវខ្ពស់នូវមុខងារទាំងអស់របស់ខ្លួន ដើម្បីឱ្យស័ក្តិសមជាតំណាងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងជាតំណាងរបស់ប្រជាជាតិខ្មែរទាំងមូល។

សមាគមអគ្គលេខាធិការសភា ទស្សនាសភាសាធារណរដ្ឋអាហ្វ្រិកខាងត្បូង

## Association of Secretaries-General of Parliaments

Visit to the Parliament of the Republic of South Africa

16 April 2008

## គណៈកម្មការកសាងសមិទ្ធផលព្រឹទ្ធសភា រយៈពេល១០ឆ្នាំ (១៩៩៩-២០០៩)

១- ឯកឧត្តម **អ៊ុំ សារិទ្ធ** ប្រធាន

២- ឯកឧត្តម **ឡោក ឆាយ** សមាជិក

៣- ឯកឧត្តម **គីម លី** សមាជិក

៤- ឯកឧត្តម **ប៊ុន ទុន្ធា** សមាជិក

៥- លោក **ឈឹម ព្រះខ័ន** សមាជិក

៦- លោក **ជួន ណា** សមាជិក

៧- លោក **អ៊ឹង ចិន្តា** សមាជិក

៨- លោកស្រី **សួន ពុធថាវី** សមាជិក

## ក្រុមរចនាម៉ូដ និងកាត់តរូបភាព

១- លោក **លី សុខមករា**

២- លោក **ណោង ករុណា**

៣- លោក **អ៊ាង ណី**

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855 23) 211441, 211442, 211443

ទូរសារ : (855 23) 211446

E-mail : oum_sarith@camnet.com.kh